ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ ភ.ស

# សារាចរ
# ស្តីពី
# ការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍

កន្លងមករាជរដ្ឋាភិបាលបានពិនិត្យឃើញថា ការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ទៅតាមច្បាប់ ជាពិសេស ការអនុវត្តព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ និងអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពតិមានវិទ្យា មិនទាន់បានប្រព្រឹត្តទៅដោយរលូននៅឡើយ ។ មានមន្ត្រីរាជការស៊ីវិលមួយចំនួន ដែលដល់អាយុចូលនិវត្តន៍ បានស្វែងរកអន្តរាគមន៍តាមរូបភាពផ្សេងៗ ដើម្បីពន្យារពេលចូលនិវត្តន៍ ។ មន្ត្រីរាជការស៊ីវិលមួយចំនួនទៀត បានធ្វើសំណើសុំប្តូរអាយុប្រាសចាក ពីឯកសារ និងសលាកប័ត្រឯកត្តជន ច្បាប់ដើម ទៅជាឆ្នាំកំណើតថ្មី ដើម្បីពន្យារពេលចូលនិវត្តន៍ ជាស្វ័យប្រវត្តិ ។

ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងប្រសិទ្ធភាព ក្នុងការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ:

១. មន្ត្រីរាជការស៊ីវិលគ្រប់រូប ដែលដល់អាយុចូលនិវត្តន៍ ត្រូវដាក់ឱ្យចូលនិវត្តន៍ ដោយអនុលោមតាមព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ ព្រមទាំងលិខិតបទដ្ឋាន ដែលនៅជាធរមាន ។

២. ការបន្ថយអាយុ និងការពន្យារពេលចូលនិវត្តន៍នៃមន្ត្រីរាជការស៊ីវិលមិនត្រូវបានអនុញ្ញាតឡើយ ។

៣. ចំពោះមន្ត្រីរាជការស៊ីវិលដែលដល់អាយុចូលនិវត្តន៍ហើយ តែមិនទាន់ដាក់ឱ្យចូលនិវត្តន៍ គ្រប់ក្រសួង ស្ថាប័ន ត្រូវដាក់មន្ត្រីរាជការស៊ីវិលទាំងនោះ ឱ្យចូលនិវត្តន៍ឱ្យបានឆាប់រហ័ស ។

គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ទាំងអស់ត្រូវសហការអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ✓
- គ្រប់ក្រសួងស្ថាប័ន
- រាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ